ប្រជាពលរដ្ឋខ្មែរ បានធ្វើការកត់សំគាល់តាំងពីច្រើនឆ្នាំមកហើយ បានឃើញថា ជនជាតិយួន ដែលរស់នៅក្នុងប្រទេសកម្ពុជាយើង ក្រៅពីបានតាំងទីលំនៅ ៗ ក្នុងទីក្រុង-ទីប្រជុំជន និងនៅតាមដងស្ទឹង-ព្រែកទន្លេ នោះ គឺមានជនជាតិយួនខ្លះបានចូលចិត្តទៅតាំងទីលំនៅៗក្នុងរូងភ្នំ, ក្នុងរោងភ្នំ ៗ

នៅប្រទេសកម្ពុជាយើង មានភ្នំច្រើន ហើយក្នុងចំណោមភ្នំទាំងនេះ មានភ្នំខ្លះមានរូង មានរោង-មានផ្ទាំងថ្មជាធំ ៗ ដែលរាជរដ្ឋាភិបាលយើងបានរៀបចំ និងគួរជាទីរៀបចំសំរាប់ជាទីកំសាន្ត ៗ តាមចាស់ទុំដំណាលថា ក្នុងចំណោមរូងភ្នំ-រោងភ្នំទាំងនេះ ពីអតីតកាលប្រជាពលរដ្ឋខ្មែរជំនាន់នោះ តែងបានឃើញលោកសង្ឃយួន-ដូនជីយួន ចាស់ក្មេង ទៅតាំងសីលសមាធិនៅទីនោះ-ហើយនៅបច្ចុប្បន្ននេះ ប្រជាពលរដ្ឋខ្មែរ ក៏បានឃើញលោកសង្ឃយួន-ដូនជីយួន នៅតាមរូងភ្នំ-រោងភ្នំខ្លះដែរ មានចំនួនច្រើននាក់ ឬតិចនាក់ ទៅតាមទីកន្លែងដែលសាមីខ្លួនយួនចូលចិត្ត ។

ជាការណ៍ពិតណាស់ នៅគ្រប់រូងភ្នំ-រោងភ្នំ-ដែលមានយួនរស់នៅ ប្រជាពលរដ្ឋខ្មែរតែងបានឃើញយួន ទាំងនោះដាប់ផ្ទាំងថ្មជាឆ្លាក់អក្សរយួនដាក់ឈ្មោះនេះឈ្មោះនោះ ឆ្នាំនេះ ឆ្នាំនោះ ដែលបណ្តាលឲ្យប្រជាពលរដ្ឋមានការងឿងឆ្ងល់យ៉ាងខ្លាំង ។

ជាកស្តុតាង មានមិត្តយើងម្នាក់ឈ្មោះ សុង-ឡេង ឃុន នៅកំពង់ត្របែក ជាអ្នកកានអ្នកជាតិនិយម បានជូនពតិមានដល់យើងថា: នៅពេលថ្មី ៗ នេះខ្លួននិងមិត្តភក្តិខ្លួនជាច្រើននាក់ បានធ្វើដំណើរទៅលេងកំសាន្តនៅភ្នំគូលែន (សៀមរាប)-លុះឡើង

ទៅដល់កំពូលភ្នំ ខ្ញុំក៏ធ្វើដំណើរតាមផ្លូវបែកទៅឆ្វេង ដែលមានសញ្ញាព្រួញចង្អុលប្រាប់កន្លែងព្រះប្រាំព្រះអង្គ ។ ក្នុងពេលនោះ ខ្ញុំបានឃើញ តាយួន-យាយយួន មួយក្រុមស្លៀកពាក់សកោរសក់ រស់នៅក្នុងកូនខ្ទមតូចៗ ប្រក់ស្បូវជិតផ្ទាំងថ្មជាធំៗ នាកន្លែងនោះ ហើយខ្ញុំក៏បានឃើញថែមទៀតដែរ នូវចម្លាក់អក្សរយួនពាសពេញលើផ្ទាំងថ្មជា ខាងស្តាំ និងខាងឆ្វេង ដែលពុំដឹងថាមានន័យយ៉ាងណា " ។ល។

នេះជាការណ៍បញ្ជាក់ឲ្យឃើញថា នៅកន្លែងណាក៏ដូចជាកន្លែងណាដែរ កាលបើមានយួនចូលទៅរស់នៅក្នុងរូងភ្នំ-ក្នុងរអាងភ្នំនោះហើយ គឺពិតជាយួនទាំងនោះបានដាប់បានឆ្លាក់អក្សរយួនពាសពេញលើថ្មជា ដែលធ្វើឲ្យប្រជាពលរដ្ឋខ្មែរដែលបានឃើញហើយមានការងឿងឆ្ងល់ និង បានបន្ទាត់ជាសំនួរថា៖ "តើជនជាតិយួនទាំងនោះ ខំព្យាយាមឆ្លាក់អក្សរយួននៅលើផ្ទាំងថ្មជានោះ ដើម្បីអ្វី? ។

ចំពោះរឿងនេះ យើងសូមលើកជូនចំពោះក្រសួងមានសមត្ថកិច្ច សូមមេត្តាពិនិត្យមើល និងបង្កើនការ ហាមឃាត់ យួន ទាំងនេះកុំឲ្យដាប់-ឆ្លាក់អក្សរយួន ឬ រូបចម្លាក់ផ្សេងៗនៅលើផ្ទាំងថ្មជាតទៅទៀត ពីព្រោះការដាប់-ឆ្លាក់បែបនេះជាហេតុនាំឲ្យខូចលំអធម្មជាតិ រូងភ្នំ-រអាងភ្នំ-ថ្មជា ហើយជាពិសេសគឺ ដើម្បីចៀសវាង កុំឲ្យ មានគ្រោះថ្នាក់ ដល់ប្រទេសកម្ពុជាទៅអនាគត ដោយសារគំនិតអាថ៌កំបាំងនៃជនជាតិយួនទាំងនេះ ។

**អ៊ូរ-ផាវង់**